**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

*ថ្ងៃ ពុធ ០៥ កើត ខែ មាឃ ឆ្នាំ កុរ ឯកស័ក ព.ស ២៥៦៣*

*រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០២០*

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពីកិច្ចពិភាក្សាការងាររវាង ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាមួយឯកឧត្តម Björn Häggmark ឯកអគ្គរាជទូតស៊ុយអែតប្រចាំព្រះរាជាណាចក្រកម្ពុជា

នារសៀលថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០២០, នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានជួបពិភាក្សាការងារជាមួយ**ឯកឧត្តម Björn Häggmark** ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពនៃប្រទេសស៊ុយអែត ប្រចាំព្រះរាជាណាចក្រកម្ពុជា នាឱកាសដែលឯកឧត្តមឯកអគ្គរាជទូតទើបចូលកាន់ដំណែង ។

នៅក្នុងជំនួបពិភាក្សានោះ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី អូន ព័ន្ធមុនីរ័ត្ន** បានសម្តែងនូវការស្វាគមន៍យ៉ាងកក់ក្តៅជូនចំពោះ**ឯកឧត្តម Björn Häggmark** ដែលត្រូវបានរដ្ឋាភិបាលស៊ុយអែតតែងតាំងជាឯកអគ្គរាជទូត ប្រចាំព្រះរាជាណាចក្រកម្ពុជា ។ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** បានវាយតម្លៃខ្ពស់ និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះរដ្ឋាភិបាល និងប្រជាជនស៊ុយអែត ដែលបានផ្តល់ជំនួយមនុស្សធម៌ដល់ប្រជាជនកម្ពុជាចាប់តាំងពីកម្ពុជា ទើបបានរំដោះចេញពីរបបប្រល័យពូជសាសន៍ ។ រាជរដ្ឋាភិបាល និងប្រជាជនកម្ពុជាចងចាំជានិច្ចចំពោះការរួមវិភាគទានដ៏ថ្លៃថ្លាក្នុងគ្រាដ៏លំបាកនោះ ។ លើសពីនេះ, រដ្ឋាភិបាលស៊ុយអែត បាន និងបន្តផ្តល់ហិរញ្ញប្បទានឥតសំណងសម្រាប់អនុវត្តគម្រោងអភិវឌ្ឍន៍ជាច្រើននៅកម្ពុជា ដោយភាគច្រើនផ្តល់ហិរញ្ញប្បទានតាមរយៈអង្គការសហប្រជាជាតិ និងសហភាពអឺរ៉ុប ។ ទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការប្រកបដោយផ្លែផ្កាវវាងប្រទេសទាំងពីរ កម្ពុជា និងស៊ុយអែត ត្រូវបានពង្រឹង និងពង្រីកឥតឈប់ឈរ ហើយបាននាំមកនូវផលប្រយោជន៍ទៅវិញទៅមកសម្រាប់ប្រទេសទាំងពីរ ។

នៅក្នុងឱកាសនោះដែរ **ឯកឧត្តមឯកអគ្គរាជទូតស៊ុយអែត Björn Häggmark** បានថ្លែងសរសើរដល់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលប្រមូលចំណូលចូលថវិការដ្ឋបានច្រើន ហើយមានការកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ ខណៈដែលប្រទេសកម្ពុជាសម្រេចបានកំណើនសេដ្ឋកិច្ចខ្ពស់ប្រកបដោយចីរភាព និងមានការអភិវឌ្ឍគួរឲ្យកត់សម្គាល់ ។ ទន្ទឹមនេះ, ការចំណាយ ថវិកាជាតិលើវិស័យសង្គមកិច្ច រួមមាន÷ ចំណាយលើវិស័យអប់រំ និងវិស័យសុខាភិបាល ក៏មានការកើនឡើងខ្លាំងផងដែរ ។ នេះគឺជាសញ្ញាវិជ្ជមានមួយនៃការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមនៅកម្ពុជា ហើយវាបានឆ្លុះបញ្ចាំងពីជោគជ័យនៃកិច្ចខិតខំប្រឹងប្រែង ធ្វើកំណែទម្រង់របស់រាជរដ្ឋាភិបាលកម្ពុជា ជាពិសេស ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងអភិបាលកិច្ច ។ ជាមួយគ្នានេះ, **ឯកឧត្តមឯកអគ្គរាជទូតស៊ុយអែត**បានលើកឡើងថា បច្ចុប្បន្នទំហំវិនិយោគដោយវិនិយោគិនស៊ុយអែតនៅកម្ពុជា នៅមានបរិមាណតិចតួចនៅឡើយ ។ ប៉ុន្តែប្រទេសទាំងពីរមានសក្តានុពលក្នុង

ការជំរុញកិច្ចសហប្រតិបត្តិការពាណិជ្ជកម្ម និងវិនិយោគ តាមរយៈការពង្រឹងកិច្ចសហប្រតិបត្តិការទ្វេភាគី និងការបង្កើនកិច្ចសន្ទនារវាង ភាគីពាក់ព័ន្ធនៃប្រទេសទាំងពីរ ។

ជាមួយគ្នានេះ, **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី អូន ព័ន្ធមុនីរ័ត្ន** បានថ្លែងអំណរគុណចំពោះរដ្ឋាភិបាលស៊ុយអែតដែលបានផ្តល់ហិរញ្ញប្បទានឥតសំណង និងជំនួយបច្ចេកទេស សម្រាប់គាំទ្រដល់កម្មវិធីកែទម្រង់របស់រាជរដ្ឋាភិបាលកម្ពុជា ជាពិសេស កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការធ្វើកំណែទម្រង់សារពើពន្ធរបស់អគ្គនាយកដ្ឋានពន្ធដារ ។ ប្រទេសស៊ុយអែតក៏បានរួមចំណែកយ៉ាងសំខាន់ផងដែរដល់ការអភិវឌ្ឍធនធានមនុស្សនៅកម្ពុជា តាមរយៈកម្មវិធីលើកកម្ពស់វិស័យអប់រំនៅកម្រិតបឋមសិក្សា និងមធ្យមសិក្សា, គម្រោងសិក្សាស្រាវជ្រាវនៅកម្រិតឧត្តមសិក្សា, និងការបណ្តុះបណ្តាលបច្ចេកទេស ដូចជា ការអភិវឌ្ឍជំនាញ និងការបង្កើតសាលាបណ្តុះបណ្តាលវិជ្ជាជីវៈម្ហូបអាហារ ជាដើម ។ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** ក៏បានជម្រាប **ឯកឧត្តមឯកអគ្គរាជទូតស៊ុយអែត**ផងដែរថា រាជរដ្ឋាភិបាលកម្ពុជាយកការធ្វើកំណែទម្រង់ជាមូលដ្ឋានគ្រឹះ និងជាបរិស្ថានក្នុងការជំរុញការអភិវឌ្ឍប្រកបដោយចីរភាព ធានាបាននូវសមធម៌សង្គម ។ រាជរដ្ឋាភិបាលកម្ពុជាក៏បានដាក់ចេញផងដែរនូវវិធានការកែទម្រង់ជាកញ្ចប់ ដើម្បីកែលម្អបរិស្ថានធុរកិច្ច និងទាក់ទាញការវិនិយោគ ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលកម្ពុជាមានសេចក្តីសោមនស្សរីករាយ ក្នុងការបន្តពង្រឹង និង ពង្រីកកិច្ចសហប្រតិបត្តិការជាមួយរដ្ឋាភិបាលស៊ុយអែត ទាំងលើផ្នែកហិរញ្ញប្បទានសម្រាប់ការអភិវឌ្ឍ ទាំងលើទំនាក់ទំនងពាណិជ្ជកម្ម និងវិនិយោគ ។

ឆ្លៀតក្នុងឱកាសនោះដែរ, ជាថ្មីម្តងទៀត **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី អូន ព័ន្ធមុនីរ័ត្ន** បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះរដ្ឋាភិបាល និងប្រជាជនស៊ុយអែត ដែលបាននិងបន្តជួយឧបត្ថម្ភគាំទ្រដល់រាជរដ្ឋាភិបាល និងប្រជាជនកម្ពុជា ហើយបានរួមចំណែកយ៉ាងធំធេងដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមនៅកម្ពុជា និងបានជូនពរសូមឲ្យ**ឯកឧត្តម Björn Häggmark** បំពេញបេសកកម្មការទូតនៅកម្ពុជា ប្រកបដោយជោគជ័យ ។